សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
# WEEKLY BULLETIN


CRF 2020/024 (ថ្ងៃទី១៣ ដល់ ១៩ ខែកក្កដា ឆ្នាំ២០២០)

CRF 2020/024 (13 to 19 July 2020)


## សង្ខេបព័ត៌មានសំខាន់ៗអំពីវិស័យស្រូវអង្ករប្រចាំសប្តាហ៍ (Rice News Briefing)

## ក្នុងប្រទេស (In Cambodia)



### កសិករមិនទទួលរងការប៉ះពាល់ពីការនាំចេញទៅអាមេរិកនោះទេ
### (Farmers 'not hurt' by exports to US)

*Phnom Penh Post: July 14, 2020*

Cambodia Rice Federation (CRF) officials have refuted claims that the Kingdom's rice exports to the US will hurt farmers there. USA Rice said the US has long provided GSP benefits to developing countries, providing duty-free access, though it is only for parboiled rice. For least-developed countries like Cambodia and Myanmar, all rice is eligible for duty-free access into the US. USA Rice submitted a petition to the Office of the US Trade Representative (USTR) in March, which has since moved forward into the formal review... (Read more)



### ការនាំចូលរបស់ទីម័រកើន២៧% ខណៈការលក់អង្ករកម្ពុជាឱ្យទីម័រនៅបន្តពន្យារពេល
### (Timor imports up 27%, Cambodian rice sale pending)

*Phnom Penh Post: July 15, 2020*

East Timor imported $597 million worth of goods last year, soaring 27 per cent from $470 million in 2018, reported Of this, 37.9 per cent came from Indonesia, 16.2 per cent from Hong Kong, 14.6 per cent from Singapore and 14.4 per cent from mainland China, the ministry's General Directorate of Statistics said in its annual External Trade Statistics Report 2019. (Read more)



### ការពិភាក្សាវិបត្តិស្តីពីការគំរាមកំហែងដល់ការនាំចូលអង្ករ
### (Crisis talks on threat to rice imports)

*Khmer Times: July 15, 2020*

The Commerce Ministry and Cambodia Rice Federation (CRF) had an urgent meeting about the USA Rice Federation to the The United States International Trade Commission (USITC) on the eliminating a trade benefit on rice imported to US including fromCambodia. The meeting was led by Seang Thay, secretary of state and the spokesman for the Ministry of Commerce, and CRF's president Song Saran, and other CRF members and commerce officials. It aims to collect all input related to the USA Rice Federation's.... (Read more)



### ចក្ខុវិស័យរបស់ OECD-FAO មើលឃើញពីសារៈសំខាន់នៃការលូតលាស់របស់ប្រទេសកម្ពុជា ទៅកាន់ទីផ្សារអង្ករសកលលោក
### (OECD-FAO Outlook Sees Growing Importance of Cambodia to Global Rice Market)

*AKP: July 16, 2020*

A medium-term outlook for agriculture released Thursday forecast that Cambodia would play an increasingly important role in the global market for rice exports. Launched in Paris, the joint report by the Organisation for Economic Cooperation and Development (OECD) and the Food and Agriculture Organisation of the United Nations (FAO) covers the 10-year period from 2020 to 2029. (Read more)



### OECD-FAO និយាយថា ទីផ្សារអង្ករកម្ពុជាកំពុងមានការកើនឡើងយ៉ាងសំខាន់ នៅក្នុងទីផ្សារផ្គត់ផ្គង់អង្ករសកលលោក
### (Cambodia's rice market to have growing importance in global rice supplies, says OECD-FAO)

*Khmer Times: July 17, 2020*

A medium-term outlook for agriculture released Thursday forecast that Cambodia would play an increasingly important role in the global market for rice exports. Launched in Paris, the joint report by the Organisation for Economic Cooperation and Development (OECD) and the Food and Agriculture Organisation of the United Nations (FAO) covers the 10-year period from 2020 to 2029. (Read more)

## អន្តរជាតិ (International)

វៀតណាម (Vietnam)

### អ្នកនាំចូលអង្ករព្យាយាមទម្លាក់តម្លៃ ខណៈវៀតណាមត្រូវការផែនការរយៈពេលវែងលើការនាំចេញអង្ករ
### (Rice importers try to force prices down, Vietnam needs long-term export plan)



*Vietnam Net: July 13, 2020*

IEarlier this month, when Mekong Delta's farmers were harvesting the 2020 summer-autumn crop, rains and storms affected rice quality and caused the market price to fluctuate. Meanwhile, the Philippines recently stated it has cancelled the plan to import 300,000 tons of rice under the G2G (government to government) mode that it opened for bidding on June 8, in which Vietnam....(Read more)

មីយ៉ាន់ម៉ា (Myanmar)

### ប្រទេសចិនបានផ្តល់អាជ្ញាប័ណ្ណនាំចេញអង្ករដល់ក្រុមហ៊ុនមីយ៉ាន់ម៉ាចំនួន ៤៣
### (China grants rice export license to 43 Myanmar companies)



*Myanmar Times: July 13, 2020*

China's customs authorities have granted rice export license to 43 Myanmar companies, local industry says.

U Soe Tun, a member of the central executive committee of the Myanmar Rice Federation, said that the general Administration of Customs of the People's Republic of China approved the license on July 10. (Read more)

ឥណ្ឌា (India)

### ការផ្តោតលើវិស័យកសិកម្ម៖ ការលេចឡើងអ្នកនាំចេញអង្កររបស់ឥណ្ឌា ពីការបិទប្រទេស
### (Agriculture Focus: Indian rice exporters' emergence from lockdown)

*S&P Global: July 14, 2020*

Labour shortages have been one of the key problems caused by the coronavirus crisis in the rice market. Robert Beaman talks to senior rice editors Rebecca Li and Peter Storey about how the Indian rice industry and its competitors have coped with access to labour during lockdown and the consequent market disruptions, while Piero Carello considers some of the lessons learnt by the agriculture sector as a result of the crisis. (Read more)

ថៃ (Thailand)

### ការរំពឹងទុកលើការនាំចេញអង្កររបស់ថៃ នៅឆមាសទី២ នឹងមិនសូវជាខ្លាំងក្លាទេ ចំពេលដែលតម្រូវការរបស់ពិភពលោកមានការជាប់គាំង
### (Prospects of Thailand's rice export in H2 "not too bright" amidst sluggish global demand: industry body)

*Xinhua net: July 15, 2020*

BANGKOK, July 15 (Xinhua) -- The Thai Rice Exporters Association on Wednesday said in a press briefing that Thailand's rice export prospects would not look too bright in the second half of the year amid sluggish global demand hit by the COVID-19 crisis.

Overall Thai rice export activity has been quiet in July after the pandemic resulted in the collapse of Phoenix Commodities, the world's biggest commodity traders, said the Association's president Charoen Laothammatas. (Read more)

ថៃ (Thailand)

### ភាពស្រពិចស្រពិលលើការនាំចេញអង្ករនៅឆមាសទី២
### (Dim view for second-half rice exports)

*Bangkok Post: July 15, 2020*




Thailand's rice export prospects look murky in the second half of the year amid sluggish global demand caused by the coronavirus crisis. Charoen Laothammatas, president of Thai Rice Exporters Association, said overall Thai rice export activity is relatively quiet in July after the pandemic resulted in the collapse of Phoenix Commodities, one of the world's biggest commodity traders. (Read more)

### អ្នកនាំចេញមានការព្រួយបារម្ភ ខណៈដែលតម្រូវការអង្ករពីបរទេសមានការយឺតយ៉ាវ

វៀតណាម ( Vietnam )

(Exporters worry as overseas demand for rice slows down)

*Saigon Times: July 15, 2020*



HCMC – Many local rice exporters have voiced concerns over the low overseas demand for rice, as they have yet to clinch any new export contract in the past few weeks amid the falling global rice prices.

A report from the Ministry of Industry and Trade showed that Vietnam's rice export value in June plunged over 53% month-on-month to some US$182 million. (Read more)

### វៀតណាមអភិវឌ្ឍប្រភេទគ្រាប់ពូជស្រូវថ្មីសម្រាប់តំបន់ទង្គ្រោះ

វៀតណាម ( Vietnam )

(VN develops new rice variety for flood and drought-prone areas)

*Nhan Dan: July 16, 2020*



NDO/VNA – The European Commission (EC) on July 15 announced quotas for several Vietnamese agricultural products and rice in line with the European Union-Vietnam Free Trade Agreement (EVFTA).

Once the deal takes effect on August 1, Vietnamese farm produce, including rice, exported to the EU will enjoy tax exemptions but they are subject to annual import quotas.(Read more)

### អង្ករ ៥ប្រភេទត្រូវបានគ្របដណ្តប់ដោយគម្រោងធានាតម្លៃថ្មី

ថៃ ( Thailand )

(Five types of rice covered by new price-guarantee scheme)

*The Nation Thailand: July 18, 2020*




The National Rice Policy Committee has approved a rice price-guarantee scheme for crop year 2020-21 for five types of rice with effect from September 1 until the end of harvesting season in May 2021, Deputy PM and Commerce Minister Jurin Laksanawisit said on Friday (July 17).

The five types of rice to be guaranteed under the scheme are:

▪ Hom Mali rice... (Read more)

## ព្រឹត្តិការណ៍ និងសកម្មភាព

## (Event and Activity)



### កិច្ចប្រជុំពិភាក្សា និងប្រមូលធាតុចូលជាបន្ទាន់ ទាក់ទងនឹងការការស្នើរបស់សហព័ន្ធស្រូវអង្ករអាមេរិក ( USA Rice Federation ) ស្នើដល់គណៈកម្មាធិការពាណិជ្ជកម្មអន្តរជាតិអាមេរិក ( USITC )លើគម្រោងញត្តិលុបចោលកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម ( GSP ) លើអង្ករនាំចូលអាមេរិក ដែលក្នុងនោះមានអង្ករកម្ពុជាផងដែរ

នាព្រឹកថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ នៅទីស្តីការក្រសួងពាណិជ្ជកម្ម **ឧកញ៉ា សុង សារ៉ន** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ឧកញ៉ា អនុប្រធានក្រុមប្រឹក្សាភិបាល ( ស.អ.ក ) រួមជាមួយ សមាជិក ស.អ.ក ចំនួន ១០ រូប បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាបន្ទាន់ ដើម្បីប្រមូលធាតុចូលទាក់ទងនឹងការដែលសហរដ្ឋអាមេរិកនឹងពិភាក្សាចុងក្រោយលើការលុបចោលកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម ( GSP ) លើអង្ករកម្ពុជា ដែលកិច្ចប្រជុំបន្ទាន់នេះ ដឹកនាំដោយ **ឯកឧត្តម ស៊ាង ថៃ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម។







ការរៀបចំកិច្ចប្រជុំបន្ទាន់នេះ គឺដើម្បីឆ្លើយតបទៅនឹងការដែលសហព័ន្ធស្រូវអង្ករអាមេរិក បានស្នើដល់គណៈកម្មការពាណិជ្ជកម្មអន្តរជាតិអាមេរិក ( USITC ) ឱ្យលុបចោលបញ្ជីទំនិញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្ថិតក្រោមប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម ( GSP )លើប្រភេទអង្ករនាំចូល ខណៈដែលកន្លងមកសហរដ្ឋអាមេរិករួមមាន ប្រទេសថៃ វៀតណាម ប្រេស៊ីល ឥណ្ឌា ភូមា និងកម្ពុជា ។

តាមការលើកឡើងពី ឧកញ៉ា សុង សារ៉ន ការនាំចូលអង្ករកម្ពុជាទៅកាន់សហរដ្ឋអាមេរិកមិនបានប៉ះពាល់ដល់កសិករសហរដ្ឋអាមេរិកនោះទេ ដោយហេតុថា ៖

- ទីមួយ បរិមាណនាំចេញអង្ករកម្ពុជាទៅកាន់សហរដ្ឋអាមេរិក គឺមានត្រឹមតែប្រមាណ២០០០ តោនប៉ុណ្ណោះក្នុងមួយឆ្នាំ។
- ទីពីរ គឺប្រភេទអង្ករដែលកម្ពុជានាំចូលទៅអាមេរិកជាប្រភេទ Indica Rice ប្រភេទសរីរាង្គ និងអង្ករក្រអូបរំដួលដែលខុសពីប្រភេទអង្ករដែលកសិករសហរដ្ឋអាមេរិកដាំដុះ ពោលគឺ Japonica Rice និង Carlrose Rice។

បន្ថែមពីលើនេះ លោក យ៉ន សុវណ្ណ សមាជិកក្រុមប្រឹក្សាភិបាលក៏បានផ្តល់ធាតុចូលមួយចំនួននៃគុណសម្បត្តិអង្ករកម្ពុជាដែលជួយដល់សុខភាពអ្នកប្រើប្រាស់ ហើយមិនគួរលុបចោលប្រព័ន្ធGSP លើការនាំចូលអង្ករកម្ពុជាក្នុងទីផ្សារសហរដ្ឋអាមេរិចនោះឡើយ។

ជាលទ្ធផល បន្ទាប់ពីអង្គប្រជុំបានពិភាក្សាផ្លាស់ប្តូរយោបល់ និងបន្តយកទៅពិភាក្សាបន្ថែមជាមួយស្ថាប័នគោលនយោបាយ និងក្រសួងពាក់ព័ន្ធនានានៅពេលខាងមុខ ដើម្បីរកដំណោះស្រាយសមស្របមួយ។

(For English Version, please click this link: https://bit.ly/2C86TfN)



# កិច្ចប្រជុំប្រឹក្សាយោបល់ជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អំពី "ការសិក្សាអំពីលទ្ធភាពបង្កើតតំបន់ពិសេសសម្រាប់វិស័យកសិ-ឧស្សាហកម្ម"

នាព្រឹកថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ **ឧកញ៉ា ចាន់ សុឃាំង** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) និងជាប្រធានគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកផ្នែកវិនិយោគ និងហិរញ្ញវត្ថុរបស់ ស.អ.ក អមជាមួយនឹង**លោក យ៉ន សុវណ្ណា** សមាជិកក្រុមប្រឹក្សាភិបាល ស.អ.ក និងលោ**ក លន់ យ៉េង** អគ្គលេខាធិការនៃលេខាធិការដ្ឋាន ស.អ.ក បានទទួលជួបសម្ដែងការគួរសមតបតាមសំណើសុំជួបប្រឹក្សាយោបល់ពីក្រុមការងារនៃអង្គភាពគ្រប់គ្រងស្រាវជ្រាវដើម្បីគាំទ្រការវិភាគវិស័យកសិកម្ម (អ.គ.ស) ក្នុងក្រមខណ្ឌ ASPIRE នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលដឹកនាំដោយ **ឯកឧត្តម រស់ សីលវ៉ា** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជានាយក អ.គ.ស ក្នុងក្របខណ្ឌ ASPIRE ដែលជំនួបនេះស្ដីអំពី "ការសិក្សាពីលទ្ធភាពបង្កើតតំបន់ពិសេសសម្រាប់វិស័យកសិ-ឧស្សាហកម្ម"។





តំណាងឱ្យសហព័ន្ធស្រូវអង្ករកម្ពុជា និងតំណាងឱ្យការយល់ឃើញពីវិស័យស្រូវអង្ករកម្ពុជា ឧកញ៉ា ចាន់ សុឃាំង បានមានប្រសាសន៍គាំទ្រពេញទំហឹង លើគំនិតក្នុងការបង្កើតឱ្យមាននូវតំបន់ពិសេស សម្រាប់វិស័យកសិ-ឧស្សាហកម្មនេះ ដែលស្រូវអង្ករកម្ពុជា គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងនេះវិស័យកសិកម្ម និងជួយដល់វិស័យសេដ្ឋកិច្ចកម្ពុជាយ៉ាងខ្ពស់គួរឱ្យកត់សម្គាល់។ នៅក្នុងជំនួបប្រឹក្សាយោបល់នេះ ឧកញ៉ា ចាន់ សុឃាំង ក៏បានលើកឡើងនូវការយល់ឃើញនានា ក៏ដូចជាផ្ដល់នូវធាតុចូលទាក់ទងនឹងបញ្ហាប្រឈម កាលានុវត្តភាព និងសំណើ/សំណូមពរផ្សេងៗ តបទៅតាមកម្រងសំណួរដែលខាងក្រុមការងារសិក្សាស្រាវជ្រាវរបស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានសាកសួរ ដើម្បីអាចឱ្យក្រុមការងារយកទៅវាយតម្លៃ និងជាគោលគំនិតសិក្សាបន្ថែមពីលទ្ធភាពក្នុងការបង្កើតតំបន់ពិសេស សម្រាប់វិស័យកសិ-ឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជានេះ។

គួរបញ្ជាក់ថា គោលបំណងនៃការសិក្សានេះ គឺដើម្បីពិនិត្យពីលទ្ធភាពនៃការបង្កើតតំបន់ពិសេសសម្រាប់ បណ្ដុំរោងចក្រកែច្នៃផលិតផលកសិ-ឧស្សាហកម្ម បម្រើឱ្យការប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ ការសិក្សានេះ នឹងសិក្សាលម្អិតបន្ថែមទៅលើតំបន់ដែលមានសក្ដានុពលក្នុងការបង្កើតតំបន់ពិសេស យន្តការគាំទ្រពីរាជរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការកំណត់នូវលក្ខខណ្ឌ និងវិធានការលើកទឹកចិត្ត រួមមានសារពើពន្ធ និងមិនមែនសារពើពន្ធ និងមេរៀនជាបទពិសោធន៍នានា ពីបណ្ដាប្រទេសដទៃទៀត។

បន្ទាប់ពីបញ្ចប់នូវកិច្ចប្រជុំប្រឹក្សាយោបល់នេះ ជំហានបន្ទាប់ ក្រុមការងារសិក្សាស្រាវជ្រាវរបស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នឹងបន្តធ្វើការស្រាវជ្រាវលម្អិតនិងស៊ីជម្រៅបន្ថែមទៀតឱ្យបានគ្រប់ជ្រុងជ្រោយ ក៏ដូចជាប្រមូលព័ត៌មាន មតិយោបល់ ធាតុចូល ពីភាគីពាក់ព័ន្ធនានា ដែលមិនមែនត្រឹមតែវិស័យស្រូវអង្ករ តែរួមទាំងវិស័យកសិកម្មទាំងមូល។ (For English Version, please click this link: https://bit.ly/3fw1ygB)

## តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
## (Paddy price & FOB Price)



សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃអង្ករនាំចេញ FOB Price
as of 20 July 2020

| Rice Varieties | Rice Standard (Price USD/ MT) 5% | 10% |
|---|---|---|
| Cambodian Jasmine Rice (Malys Angkor) | 910 | |
| Standard Fragrant Rice_SKO | 780 | |
| White Rice_Premium (Soft cooking) | 530 | |
| Parboiled Rice | 560 | |
| Organic Parboiled Rice | 1000 | |
| Organic White Rice | 950 | |
| Organic Jasmine Rice (Malys Angkor) | 1400 | |
| Organic Brown Jasmine Rice (Premium Quality) | | 1370 |

Source : Cambodian Exporters and Millers
Note: Price Fluctuation : +/- 2%



សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃស្រូវសើម នៅតាមទីតាំង
ដែលកំពុងប្រមូលផល តាមបណ្ដាខេត្តមួយចំនួន
ថ្ងៃចន្ទ ទី២០ ខែកក្កដា ឆ្នាំ២០២០

| ខេត្ត | ស្រុក | ស្រូវសែនក្រអូប | ស្រូវអ៊ីអែរ | ស្រូវផ្សេងៗ |
|---|---|---|---|---|
| កំពង់ចាម | ស្ទឹងត្រង់ ** | ១១០០ | | |
| កំពង់ធំ | សន្ទុក<br>ស្ទឹងសែន *** | | *៨៤០<br>*៨៥០ | |
| បាត់ដំបង | បាណន់ **** | ១២០០ | | |
| ប៉ៃលិន | សាលាក្រៅ | | | ៩៥០ |
| តាកែវ | កោះអណ្ដែត | | *៨៩០<br>៨៧០ | |
| ព្រៃវែង | បាភ្នំ ***** | ១១៥០ | *៨៣០<br>៨៥០ | |

គិតឯកតាជារៀល/គីឡូក្រាម

សម្រាប់អ្នកដែលមានបំណងទំនាក់ទំនងទិញស្រូវ អាចទាក់ទង៖
សហគមន៍កសិកម្មសំបូរមានជ័យ (ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម) 077 996 768
សហគមន៍កសិកម្មអូរកន្ទួមានជ័យ (សង្កាត់អូរកន្ទួ ក្រុងស្ទឹងសែន) 012 214 628
សហគមន៍កសិកម្មអាងកំពឹងពួយ (ស្រុកបាណន់ ខេត្តបាត់ដំបង) 012 824 665
សហគមន៍កសិកម្មពន្លឺបេងក្រពុំឈូក (ស្រុកកោះអណ្ដែត ខេត្តតាកែវ) 088 684 8567
សហគមន៍កសិកម្មបាភ្នំមានជ័យ (ស្រុកបាភ្នំ ខេត្តព្រៃវែង) 012 344 631

កំណត់សម្គាល់៖
*ពូជស្រូវអូអឹម 5451 **សហគមន៍កសិកម្មសំបូរមានជ័យ (077 996 768) បាននឹងកំពុងប្រមូលផលស្រូវសែនក្រអូប ប្រមាណ ២០០ហិកតា។

## សហព័ន្ធស្រូវអង្ករកម្ពុជា (Cambodia Rice Federation)

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
*លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)*

**ប្រធានសហព័ន្ធ (President)**
*លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)*

**អគ្គលេខាធិការ (Secretary General)**
*លោក លន់ យ៉េង (Mr. Lun Yeng)*

**រៀបរៀង និងចងក្រងដោយ (Compiled by)**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*

**កែសម្រួលដោយ (Edited by)**
*- លោក ខេ ឡុងម៉េង - មន្ត្រីសម្របសម្រួលគណៈកម្មាធិការប្រតិបត្តិ ស.អ.ក និងការងារប្រចាំតំបន់១&២ (Mr. Khe Longmeng - Executive Committees Coordinator and Zone 1&2 Coordinator)*
*- កញ្ញា ធុន ស្រីមុំ - ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ (Ms. Thun Sreymom - Admin and Finance Manager)*

**រចនាដោយ (Designed by)**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*


(855) 23 559 8999
info@crf.org.kh
Soma Tower, 7th Floor #2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia
https://www.facebook.com/cambodiaricefederation/
www.crf.org.kh
https://twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation